# សេចក្តីប្រកាសព័ត៌មាន

## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់មណ្ឌលសិក្សាចំនួន ៣ ទីតាំង

## កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណិត

**កម្មវត្ថុ** ៖ ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវមណ្ឌលសិក្សាចំនួន៣ នៃកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណិត (ប៊ីប)

**គណៈអធិបតី** ៖

- ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋលេខាធិការប្រចាំការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- លោក **Sardar Umar Alam** អ្នកតំណាងអង្គការយូណេស្កូនៅកម្ពុជា
- តំណាងក្រសួងអប់រំ យុវជន និងកីឡា
- តំណាងក្រុមហ៊ុន Smart Axiata
- ក្រុមការងារផ្តួចផ្តើមកម្មវិធីរបស់អង្គការសហប្រជាជាតិស្តីពីការងារយុវជន អង្គការអប់រំពិភពលោក និងអង្គការក្រៅរដ្ឋាភិបាលដែលផ្តោតលើយុវវ័យ

**កាលបរិច្ឆេទ** ៖ ថ្ងៃព្រហស្បត្តិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៩ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១១:០០ព្រឹក

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ (**NIEI** )

---

មិត្តអ្នកសារព័ត៌មានជាទីមេត្រី,

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យអង្គការយូណេស្កូភ្នំពេញ មានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការមណ្ឌលសិក្សានៃកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណិត (ប៊ីប) ៣ទីតាំងបន្ថែមទៀតនៅរាជធានីភ្នំពេញ៖

១. វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ ( NIEI )

២. វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ( NIB )

៣. សាលាមធ្យមសិក្សាបច្ចេកទេស JVC

កម្មវិធីនេះនឹងប្រារព្ធឡើងនៅថ្ងៃព្រហស្បត្តិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៩ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១១:០០ព្រឹក នៅវិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ (NIEI) បន្ទាប់ពីបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការមណ្ឌលសិក្សាចំនួន ៤ទីតាំង នាពេលថ្មីៗកន្លងទៅនេះ។

កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណិត គឺជាការផ្តួចផ្តើមរួមគ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ ដើម្បីផ្តល់នូវការអប់រំ ដែលមានភាពបត់បែនដល់

យុវជនដែលបានបោះបង់ចោលការសិក្សា ដើម្បីឱ្យពួកគេបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន ដែលមានតម្លៃស្មើនឹងថ្នាក់ទី៩។ កម្មវិធីប៊ីបនឹងជួយយុវជនកម្ពុជាឱ្យបន្តការសិក្សារបស់ពួកគេ ស្របពេលដែលកំពុងបំពេញការងារផ្ទាល់ខ្លួន។ ការទទួលបាននូវការអប់រំមូលដ្ឋាននឹងជួយឱ្យពួកគេមានចំណេះដឹង និងជំនាញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងបំណិនជីវិត។

គិតត្រឹមរយៈពេល២ខែ បន្ទាប់ពីមណ្ឌលសិក្សាទី១នៅរាជធានីភ្នំពេញត្រូវបានដាក់សម្ពោធឱ្យដំណើរការជាផ្លូវការនៅខែកុម្ភៈកន្លងទៅនេះ មានសិស្សចំនួន ៧៣៤ នាក់ ដែលមកពីទីកន្លែងនានានៃប្រទេសកម្ពុជាបានចុះឈ្មោះសិក្សាតាមប្រព័ន្ធអនឡាញ(សិស្សស្រី ២៥%) និងសិស្សដែលកំពុងសិក្សានៅ ៤ មណ្ឌលមានចំនួន ៦០ នាក់។

ដោយឡែក មណ្ឌលសិក្សាចំនួន០៥ នៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំរួចរាល់សម្រាប់ដំណើរការបណ្តុះបណ្តាលនិងកំពុងធ្វើការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗដល់ក្រុមគោលដៅ ដើម្បីមកចុះឈ្មោះចូលរៀនក្នុងកម្មវិធីប៊ីបនេះ។ បច្ចុប្បន្ន សិស្សដែលកំពុងសិក្សាមានចំនួន៣២នាក់ (ស្រី១០នាក់) (គិតត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩) និងបន្តការចូលរៀនជាបន្តបន្ទាប់។

ក្នុងអំឡុងពេលជប់ពីរខែកន្លងមកនេះ ប៊ីប បានបង្កើតនូវកិច្ចសន្ទនាប្រកបដោយភាពរស់រវើកអំពីសារៈសំខាន់នៃការបន្តការសិក្សា និងការអប់រំពេញមួយជីវិត នៅកម្ពុជាក្នុងចំណោមអ្នកបង្កើតគោលនយោបាយ និយោជក ដៃគូអភិវឌ្ឍន៍ និងយុវជន។ ក្នុងនោះមានអ្នកស្ម័គ្រចិត្តវ័យក្មេង ១៧នាក់ ដែលនៅជួយសម្របសម្រួលក្នុងកម្មវិធីប៊ីប និងមានអ្នកគាំទ្រចំនួន ៨ ៦៨៨ នាក់ក្នុងគេហទំព័រ Facebook។ ក្រុមការងារប៊ីប មានសេចក្តីរំភើបចំពោះការរីកចម្រើននេះ។

ដោយមានការគាំទ្រពីក្រុមការងារផ្តួចផ្តើមកម្មវិធីរបស់អង្គការសហប្រជាជាតិស្តីពីការងារយុវជននៅកម្ពុជា វគ្គសិក្សាប៊ីប ត្រូវបានដាក់បញ្ចូលនៅលើកម្មវិធី Moodle ជាភាសាខ្មែរ ដែលមានការសហការរវាង ប៊ីប និងមជ្ឈមណ្ឌល EdTech នៃអង្គការអប់រំពិភពលោក ក្នុងនោះមានវគ្គសិក្សាអេឡិចត្រូនិកចំនួន ១១ មុខវិជ្ជា សម្រាប់សិស្សជ្រើសរើសសិក្សា។ ប៊ីប នឹងត្រូវបានដាក់ឱ្យដំណើរការនៅក្នុង ១០ មណ្ឌលសិក្សា (៥ នៅរាជធានីភ្នំពេញ និង ៥ នៅខេត្តសៀមរាប) ។ សិស្សដែលបានចុះឈ្មោះនឹងត្រូវបានផ្តល់ជូននូវសេវាអ៊ិនធឺណិត ដោយ Smart Axiata ដោយឥតគិតថ្លៃសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមតម្រូវការរបស់ពួកគេ។ សិស្សដែលបានបញ្ចប់មុខវិជ្ជាទាំងអស់ដោយជោគជ័យ និងឆ្លងកាត់ការវាស់ស្ទង់សមត្ថភាពតាមរយៈការប្រឡងនឹងទទួលបានវិញ្ញាបនបត្រអប់រំមូលដ្ឋាន ហើយមានឱកាសបន្តការសិក្សារបស់ពួកគេទាំងនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ឬក៏នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ។

ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋលេខាធិការប្រចាំការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើជាអធិបតីនៃកម្មពិធីនេះ ដោយមានវត្តមានមន្ត្រីជាន់ខ្ពស់មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងក្រសួងអប់រំ យុវជន និងកីឡា អង្គការ UNESCO ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យអភិវឌ្ឍយុវជនផងដែរ។ បទបង្ហាញ និងខ្សែវីដេអូខ្លីអំពីវឌ្ឍនភាពកម្មវិធី នឹងចាក់បង្ហាញជូនទស្សនាដល់ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់ផងដែរ។

*សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងមក:*

1. អ្នកស្រី ឡុង សុផាន ការិយាល័យបណ្តុះបណ្តាលពិសេស និងយេនឌ័រ, longsophan@gmail.com, 092 676 776
2. លោក លៀវ គឹមឡាយ មន្ត្រីកម្មវិធីអប់រំនៃអង្គការយូណេស្កូ k.leav@unesco.org, 069 891 234